**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តឧត្តរមានជ័យ**

លេខ: ០១០៥ សជណ.ឧជ

ឧត្តរមានជ័យ,ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២

**ជម្រាបមក**

**លោកអភិបាលក្រុង / ស្រុក - លោកចៅសង្កាត់ / មេឃុំ ទាំងអស់ក្នុងខេត្តឧត្តរមានជ័យ**

**កម្មវត្ថុ:** ស្តីពីការប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់ដីមិនចុះបញ្ជី(គ្មានប័ណ្ណកម្មសិទ្ធិ) ក្រោមរូបភាពជាការលក់ ការដោះដូរ និង ការទទួលអំណោយ ដែលចុះហត្ថលេខាដោយចៅសង្កាត់ / មេឃុំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ គណៈអភិបាលខេត្តបានពិនិត្យឃើញថា ជារៀងរាល់ខែរាល់ឆ្នាំ ការទិញលក់ដីមិនចុះបញ្ជីមានចំនួនច្រើន ប៉ុន្តែម្ចាស់ដីមួយចំនួនមិនបានទៅបង់ពន្ធប្រថាប់ត្រាឡើយ ដែលធ្វើអោយបាត់ចំណូលថវិកាខេត្តមួយចំនួនធំ ។ មាត្រា ៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ១៩៩៥ បានកំណត់ថា " ការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ រឺ ការផ្ទេរសិទ្ធិកាន់កាប់ដីក្រោមរូបភាពជាការលក់ ការដោះដូរ ការទទួលអំណោយ ការដាក់ភាគទុនក្នុងក្រុមហ៊ុន ត្រូវតែបង់ពន្ធប្រថាប់ត្រា " (៤% លើតម្លៃទិញដាក់ស្តែង) ។

អភិបាលខេត្តនឹងបញ្ជូនមន្ត្រីពន្ធដារ ដើម្បីពិនិត្យសៀវភៅលេខចេញនៅសង្កាត់ / ឃុំ រៀងរាល់ខែ ករណីពិនិត្យឃើញថា ចៅសង្កាត់ / មេឃុំ បានចុះហត្ថលេខាបញ្ជាក់ លើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីមិនចុះបញ្ជីមុនពេលបង់ពន្ធប្រថាប់ត្រានោះ ចៅសង្កាត់ / មេឃុំ ត្រូវចេញសងថ្លៃពន្ធប្រថាប់ត្រា ហើយត្រូវពិន័យជាប្រាក់មួយដង ស្មើប្រាក់ពន្ធត្រូវបង់ និង ត្រូវទទួលខុសត្រូវចំពោះមុខអាជ្ញាធរសវនកម្មជាតិ ។

អាស្រ័យហេតុនេះ សូមលោកអភិបាលក្រុង / ស្រុក ចៅសង្កាត់ / មេឃុំ ស្មៀនសង្កាត់ / ឃុំ មេត្តាជួយជំរុញម្ចាស់ដីទាំងអស់អោយទៅបង់ពន្ធនៅអង្គភាពពន្ធដារ ដើម្បីបង្កើនចំណូលថវិកាខេត្ត ។ ចំពោះស្មៀនសង្កាត់ / ឃុំ បើសិនចៅសង្កាត់ / មេឃុំ ចុះហត្ថលេខាបំពានការណែនាំនេះ មិនត្រូវបោះត្រាឲ្យឡើយហើយត្រូវរាយការណ៍តាមទូរសព្ទមកសាលាខេត្ត ឬ មន្ត្រីពន្ធដារ ដើម្បីជួយអន្តរាគមន៍ ។

ទទួលបានការជូនដំណឹងនេះ សូមលោកអភិបាលក្រុង / ស្រុក ចៅសង្កាត់/ មេឃុំ មេត្តាជួយណែនាំដល់មន្ត្រីក្រោមឱវាទ ដើម្បីអនុវត្តការងារនេះអោយបានម៉ឺងម៉ាត់ជាទីបំផុត ។

សូមលោកអភិបាលក្រុង / ស្រុក ចៅសង្កាត់ / មេឃុំ ស្មៀនសង្កាត់ / ឃុំ ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**អភិបាលខេត្ត**

**ប៊ិច_សុខិន**

**ចំលងជូន:**

-ក្រសួងមហាផ្ទៃ

-អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-សាខាពន្ធដារខេត្តឧត្តរមានជ័យ (ដើម្បីអនុវត្ត)

-ឯកសារ-កាលប្បវត្តិ